នស/រកត/០៩០៥/៣៩៦

# ព្រះរាជក្រឹត្យ
## ស្ដីពី
## ការបង្កើតគណៈទន្តពេទ្យកម្ពុជា

### យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រង លើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី នាថ្ងៃ២៩ ខែកក្កដា ឆ្នាំ២០០៥

### ត្រាស់បង្គាប់

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតគណៈទន្តពេទ្យមួយ ដើម្បីប្រមូលផ្តុំទន្តពេទ្យទាំងអស់ដែលមាននីតិសម្បទាគ្រប់គ្រាន់អាចប្រកបវិជ្ជាជីវៈទន្តសាស្ត្រនៅព្រះរាជាណាចក្រកម្ពុជា ។

ពាក្យថាទន្តពេទ្យក្នុងព្រះរាជក្រឹត្យនេះគឺ នីតិជនដែលមានសញ្ញាប័ត្រទន្តសាស្ត្រចេញដោយក្រសួងសុខាភិបាល ឬក្រសួងអប់រំយុវជន និងកីឡា ឬសញ្ញាប័ត្រទន្តសាស្ត្រចេញដោយគ្រឹះស្ថានឧត្តមសិក្សា ដែលបានទទួលស្គាល់គុណភាពអប់រំ ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ។

ទន្តពេទ្យទាំងអស់ដែលប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ត្រូវសុំចុះឈ្មោះនៅក្នុងបញ្ជីគណៈទន្តពេទ្យ ។

## ជំពូកទី ២
## បេសកកម្មរបស់គណៈទន្តពេទ្យ

**មាត្រា ២.-**

គណៈទន្តពេទ្យ ត្រូវឃ្លាំមើលការប្រព្រឹត្តទៅនៃបណ្តាគោលការណ៍សីលធម៌ ភាពសុចរិតយុត្តិធម៌ និងភក្តីភាពចាំបាច់ក្នុងការប្រកបវិជ្ជាជីវៈទន្តសាស្ត្រឱ្យបានគង់វង្ស និងមានប្រសិទ្ធភាព ។

គណៈទន្តពេទ្យ ត្រូវឃ្លាំមើលការប្រតិបត្តិរបស់សមាជិកខ្លួនទាំងអស់ ចំពោះករណីយកិច្ចវិជ្ជាជីវៈព្រមទាំងបទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងក្រមសីលធម៌ទន្តពេទ្យ ។

គណៈទន្តពេទ្យធានាការពារកិត្តិយស និងឥស្សរភាពរបស់វិជ្ជាជីវៈទន្តសាស្ត្រ ។

គណៈទន្តពេទ្យបំពេញភារកិច្ចរបស់ខ្លួនតាមរយៈក្រុមប្រឹក្សាគណៈទន្តពេទ្យខេត្ត ក្រុង ក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ និងក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ។

## ផ្នែកទី ១
## តួនាទីសីលធម៌

**មាត្រា ៣.-**

គណៈទន្តពេទ្យមានបន្ទុករៀបរៀងក្រមសីលធម៌ទន្តពេទ្យ យកលំនាំតាមលក្ខណៈចាំបាច់នៃវិជ្ជាជីវៈ ក្នុងការវិវត្តន៍ខ្ជាប់ខ្ជួនខាងបច្ចេកទេសសេដ្ឋកិច្ច និងសង្គមកិច្ចដែលត្រូវធ្វើអោយវិវត្តន៍ល្អក្នុងផលប្រយោជន៍របស់អ្នកជម្ងឺ ។

គណៈទន្តពេទ្យតាមឃ្លាំមើលរាល់ការប្រតិបត្តិកិច្ចការ និងសេចក្តីគោរពប្រណិបត្តិ ។

គណៈទន្តពេទ្យជាអង្គការស្វយ័តការចំណាយការផ្គត់ផ្គង់ប្រាក់កាស ម្ចាស់ការខ្លួនឯង ធានាឥស្សរភាព ការពារផលប្រយោជន៍សីលធម៌វិជ្ជាជីវៈ ។

## ផ្នែកទី ២
## តួនាទីគ្រប់គ្រងរដ្ឋបាល

**មាត្រា ៤.-**

ការចាត់ចែងអំណាចត្រូវអនុលោមតាមបញ្ជាគណៈទន្តពេទ្យ ។

គណៈទន្តពេទ្យត្រូវរៀបចំធ្វើ និងថែរក្សាទុកជាប្រចាំនូវបញ្ជីរាយនាមទន្តពេទ្យដែលបានចុះឈ្មោះបំពេញល័ក្ខខ័ណ្ឌច្បាប់ និងសីលធម៌ចាំបាច់ ។

កាតព្វកិច្ចនៃការចុះឈ្មោះ ក្នុងបញ្ជីរាយនាមទន្តពេទ្យ គឺដើម្បីបំពេញការរៀបចំថែទាំព្យាបាលជម្ងឺ ។

គណៈទន្តពេទ្យជាអង្គការវិជ្ជាជីវៈតែមួយគត់ ដែលមានមុខងារតាមឃ្លាំមើលល័ក្ខខ័ណ្ឌនៃការប្រកបវិជ្ជាជីវៈទន្តពេទ្យនេះ ។

## ផ្នែកទី ៣
## តួនាទីសម្រេចសេចក្តីតាមបែបតុលាការ

**មាត្រា ៥.-**

បណ្តឹងអំពីការប្រព្រឹត្តខុសឆ្គងនៃមុខវិជ្ជាជីវៈរបស់ទន្តពេទ្យណាមួយទៅគណៈទន្តពេទ្យ មិនមែនជាឧបសគ្គក្នុងការធ្វើបណ្តឹងចំពោះការប្រព្រឹត្តខុសឆ្គងនេះ ទៅតុលាការឡើយ ។

## ផ្នែកទី ៤
## តួនាទីពិគ្រោះផ្តល់យោបល់

**មាត្រា ៦.-**

គណៈទន្តពេទ្យអាចត្រូវបានកោះហៅអោយផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងវិជ្ជាជីវៈទន្តពេទ្យទាំងឡាយ ។

## ផ្នែកទី ៥
## តួនាទីជួយសម្រុះសម្រួលទៅវិញទៅមក



៤/១៣

**មាត្រា ៧.-**

ការជួយសង្គ្រោះគ្នាទៅវិញទៅមកនេះមានបច្ច័យដល់ទន្តពេទ្យ និងគ្រួសារទន្តពេទ្យ ។

ការជួយសង្គ្រោះគ្នាបានរៀបចំតាមបែបបទដូចតទៅ ÷

-ក្រុមប្រឹក្សាគណៈទន្តពេទ្យកម្ពុជាត្រូវមានក្នុងថវិការបស់ខ្លួន ប្រាក់បម្រុងសម្រាប់ជួយសង្គ្រោះគ្នាទៅវិញទៅមក ដើម្បីអនុញ្ញាតអោយប្រើប្រាស់ប្រាក់បម្រុងជាជំនួយភ្លាមៗ ក្នុងករណីសមរម្យដល់គ្រួសារទន្តពេទ្យដែលត្រូវរងទុក្ខលំបាក ។

-ក្រុមប្រឹក្សានេះត្រូវមានគណៈកម្មការមួយជួយសង្គ្រោះគ្នាទៅវិញទៅមក ដែលមានតំណាងសមាគមទន្តពេទ្យកម្ពុជាម្នាក់ជាសមាជិក ។

-គណៈកម្មការនេះ ច្បាស់ចែងអោយមានធនធានប្រចាំឆ្នាំ ដែលកាត់យកខ្លះពីប្រាក់វិភាគទានពីទន្តពេទ្យម្នាក់ៗដែលចុះឈ្មោះ ក្នុងគណៈទន្តពេទ្យ ។

## ជំពូកទី ៣

## រចនាសម្ព័ន្ធ

## ផ្នែកទី ១

## ក្រុមប្រឹក្សាគណៈទន្តពេទ្យថ្នាក់ខេត្ត ក្រុង

**មាត្រា ៨.-**

ក្រុមប្រឹក្សាគណៈទន្តពេទ្យថ្នាក់ខេត្ត ក្រុងដែលសរសេរកាត់ថា ក.ទ.ខ.ត្រូវបង្កើតនៅតាមខេត្ត ក្រុងនីមួយៗនៅ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ចំពោះខេត្ត ក្រុង ដែលមានចំនួនទន្តពេទ្យតិចជាងដប់ (១០)នាក់ ត្រូវបញ្ចូលទៅខេត្តដែលនៅជិតជាងគេ ដើម្បីបង្កើតក្រុមប្រឹក្សាគណៈទន្តពេទ្យ ។

**មាត្រា ៩.-**

ក.ទ.ខ. ត្រូវមានសមាជិកពេញសិទ្ធិចំនួនបី(០៣)រូប និងសមាជិកជំនួសចំនួនបី(០៣)រូប ក្នុងករណីដែលចំនួនទន្តពេទ្យដែលបានចុះឈ្មោះក្នុងបញ្ជីមានមិនលើសពីសាមសិប (៣០)នាក់ ។ ចំនួននេះនឹងឡើងទៅដល់ប្រាំ, ប្រាំបួន, ដប់មួយ, ដប់ប្រាំ, ដប់ប្រាំបួន, ម្ភៃមួយរូប បើសិនជាចំនួនទន្តពេទ្យនៅក្នុងបញ្ជីមានលើសពីសាមសិប, ហាសិប, មួយរយ, ប្រាំរយ, មួយពាន់, ពីរពាន់នាក់ ។

**មាត្រា ១០.-**

ក.ទ.ខ. ត្រូវបានបោះឆ្នោតជ្រើសរើសនៅក្នុងអង្គមហាសន្និបាត ដោយបណ្តាទន្តពេទ្យដែលបានចុះឈ្មោះនៅក្នុងបញ្ជីរបស់ ក.ទ.ខ. សម្រាប់រយៈពេលប្រាំមួយ (០៦) ឆ្នាំ ។



13

សមាជិកចប់អាណត្តិ អាចឈរឈ្មោះអោយគេបោះឆ្នោតជ្រើសរើសសារជាថ្មីឡើងវិញបាន ។ ក្រុមប្រឹក្សាធ្វើការបោះឆ្នោតជ្រើសរើសប្រធាន និងការិយាល័យរបស់ខ្លួននៅក្នុងរយៈពេលពីរ (០២) ឆ្នាំម្តង ក្រោយពីបានធ្វើការផ្លាស់ប្តូរចំនួន១/៣ នៃសមាជិករបស់ក្រុមប្រឹក្សា ។ ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង ក្នុងករណីដែលចំនួនសមាជិកផ្លាស់ប្តូរមានចំនួនចែកមិនដាច់ ។

ការិយាល័យរបស់ ក.ទ.ខ. រួមមាន ប្រធានក្រុមប្រឹក្សាមួយរូប អនុប្រធានមួយរូប លេខាធិការមួយរូប ហិរញ្ញិកមួយរូប និងសមាជិកមួយរូប ។

**មាត្រា ១១.-**

ក.ទ.ខ. បំពេញការងារនៅក្នុងក្របខ័ណ្ឌខេត្ត ក្រុងរបស់ខ្លួន និងក្រោមការត្រួតពិនិត្យរបស់គណៈទន្តពេទ្យជាតិចំពោះសមត្ថកិច្ចទូទៅទាំងឡាយ ដែលមានចែងនៅក្នុងមាត្រា២ នៃព្រះរាជក្រឹត្យនេះ ។ ក.ទ.ខ. សម្រេចអារកាត់ក្នុងការចុះឈ្មោះទន្តពេទ្យដែលបានបំពេញល័ក្ខខ័ណ្ឌតាមមាត្រា៣ ជំពូកទី១ មាត្រា៦ ជំពូកទី២ នៃច្បាប់ស្តីពីការគ្រប់គ្រងការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ជំនួយវេជ្ជសាស្ត្រ នៅក្នុងបញ្ជីរបស់គណៈទន្តពេទ្យ ។ ក.ទ.ខ. មិនប្រកាន់ភេទ ជំនឿសាសនា និន្នាការនយោបាយ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតរបស់សមាជិកខ្លួនឡើយ ។

**មាត្រា ១២.-**

ក.ទ.ខ. ពុំមានអំណាចដាក់វិន័យទេ បើមានពាក្យបណ្តឹងចំពោះទន្តពេទ្យដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ក.ទ.ខ. ត្រូវបញ្ជូនបណ្តឹងនោះទៅក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ ដោយបញ្ជាក់ហេតុផលច្បាស់លាស់ ។

**មាត្រា ១៣.-**

ប្រធានតំណាងឱ្យ ក.ទ.ខ. នៅក្នុងគ្រប់សកម្មភាពស៊ីវិល ។

**មាត្រា ១៤.-**

ការប្រជុំនៃក្រុមប្រឹក្សាគណៈទន្តពេទ្យខេត្ត ក្រុង នឹងមិនធ្វើជាសាធារណៈឡើយ ។ កាលណាមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធានមានឧត្តមានុភាពសម្រេច ។ ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ត្រូវបានអញ្ជើញចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា គ្រាន់តែមានសម្លេងពិគ្រោះយោបល់ ។ ក.ទ.ខ. អាចអញ្ជើញទីប្រឹក្សាច្បាប់មួយរូបចូលរួមក្នុងអង្គប្រជុំ ។

**មាត្រា ១៥.-**

ទន្តពេទ្យប្រកបវិជ្ជាជីវៈទន្តសាស្ត្រនៅតាមបណ្តាខេត្ត ក្រុង ត្រូវដាក់ពាក្យសុំចុះឈ្មោះនៅក្នុងបញ្ជីដែលកាន់កាប់ជាប្រចាំដោយក្រុមប្រឹក្សាគណៈទន្តពេទ្យខេត្ត ក្រុងពាក់ព័ន្ធ ។ អាចចុះឈ្មោះនៅក្នុងបញ្ជីគណៈទន្តពេទ្យតែចំពោះទន្តពេទ្យដែលមានសញ្ញាប័ត្រទន្តសាស្ត្រចេញដោយក្រសួងសុខាភិបាល ឬក្រសួងអប់រំយុវជន និងកីឡា ឬសញ្ញាប័ត្រ

ចេញដោយគ្រឹះស្ថានឧត្តមសិក្សា ដែលទទួលស្គាល់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ក្នុងការប្រកបវិជ្ជាជីវៈទន្តសាស្ត្រ និងបានបំពេញល័ក្ខខ័ណ្ឌច្បាប់ និងក្រមសីលធម៌ដែលបានកំណត់ ។

ទន្តពេទ្យអាចចុះឈ្មោះបានតែនៅក្នុងបញ្ជីនៃខេត្ត ក្រុង ដែលជាកន្លែងប្រកបវិជ្ជាជីវៈរបស់ខ្លួនតែប៉ុណ្ណោះ ។

**មាត្រា ១៦.-**

គ.ទ.ខ. ត្រូវសម្រេចលើការសុំចុះឈ្មោះក្នុងរយៈពេលយ៉ាងយូរបី (០៣)ខែ ដោយគិតចាប់តាំងពីថ្ងៃទទួលពាក្យដែលមានឯកសារគ្រប់គ្រាន់ ។

ក្នុងរយៈពេលមួយសប្តាហ៍យ៉ាងយូរក្រោយការសម្រេច ក្រុមប្រឹក្សាត្រូវជូនដំណឹងតាមលិខិតអនុសាសន៍ទៅទន្តពេទ្យសាមី ។ បើមានការបដិសេធសេចក្តីសម្រេចត្រូវមានមូលហេតុច្បាស់លាស់ ។

ការអនុញ្ញាតឱ្យចុះឈ្មោះនៅក្នុងបញ្ជីគណៈទន្តពេទ្យខេត្ត ក្រុងនីមួយៗ ត្រូវជូនដំណឹងយ៉ាងឆាប់បំផុតទៅអាជ្ញាធរខេត្ត ក្រុង ទៅព្រះរាជអាជ្ញានៃខេត្ត ក្រុងពាក់ព័ន្ធ និងទៅក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ។

**មាត្រា ១៧.-**

ក្រោយពីបានការអនុញ្ញាតអោយចុះឈ្មោះនៅក្នុងបញ្ជីគណៈទន្តពេទ្យខេត្ត ក្រុង ដែលខ្លួនរស់នៅហើយ ទន្តពេទ្យអាចប្រកបវិជ្ជាជីវៈទន្តសាស្ត្រនៅខេត្ត ក្រុង ដែលខ្លួនបានចុះឈ្មោះប៉ុណ្ណោះ ។ ក្នុងករណីមានការផ្លាស់ប្តូរលំនៅស្ថានវិជ្ជាជីវៈទៅក្រៅខេត្ត ក្រុង ដែលខ្លួនបានសុំចុះឈ្មោះទន្តពេទ្យ ត្រូវជូនដំណឹងទៅក្រុមប្រឹក្សាចាស់ និងត្រូវធ្វើពាក្យសុំចុះឈ្មោះសារជាថ្មី ទៅក្រុមប្រឹក្សាខេត្ត ក្រុង ដែលខ្លួនទៅរស់នៅ ។

**មាត្រា ១៨.-**

ក្រុមប្រឹក្សាគណៈទន្តពេទ្យខេត្ត ក្រុង ត្រូវទទួលបណ្តឹងជំទាស់ពីក្រុមប្រឹក្សាជាតិ សមាគមទន្តពេទ្យ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ព្រះរាជអាជ្ញាអមតុលាការ ឬទន្តពេទ្យណាម្នាក់ ដែលបានចុះឈ្មោះនៅក្នុង បញ្ជីគណៈទន្តពេទ្យ រួចហើយធ្វើរបាយការណ៍ផ្ញើជូនគណៈទន្តពេទ្យជាតិ ។

## ផ្នែកទី ២
## ក្រុមប្រឹក្សាគណៈទន្តពេទ្យថ្នាក់ភូមិភាគ

**មាត្រា ១៩.-**

ការបែងចែកភូមិភាគសម្រាប់គណៈទន្តពេទ្យកម្ពុជានេះ ត្រូវបានរៀបចំដូចខាងក្រោម ÷

ភូមិភាគ ១ : រួមមាន រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង មានទីតាំងនៅរាជធានីភ្នំពេញ ។

ភូមិភាគ ២ : មានខេត្តពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងក្រុងប៉ៃលិន មានទីតាំងនៅខេត្តបាត់ដំបង ។

ភូមិភាគ ៣ : មានខេត្តតាកែវ កំពត កោះកុង ក្រុងព្រះសីហនុ និងក្រុងកែប មានទីតាំងនៅខេត្តកំពត ។
ភូមិភាគ ៤ : មានខេត្តស្ទឹងត្រែង រតនៈគិរី មណ្ឌលគិរី ក្រចេះ និងព្រះវិហារ មានទីតាំងនៅខេត្តស្ទឹងត្រែង ។
ភូមិភាគ ៥ : មានខេត្តកំពង់ចាម កំពង់ធំ ព្រៃវែង និងស្វាយរៀង មានទីតាំងនៅខេត្តកំពង់ចាម ។

**មាត្រា ២០.-**

ក្រុមប្រឹក្សាគណៈទន្តពេទ្យថ្នាក់ភូមិភាគសរសេរកាត់ថា គ.ទ.ភ. មានតួនាទីជាក្រុមប្រឹក្សាវិន័យវិជ្ជាជីវៈថ្នាក់បឋមមានសមាជិកពេញសិទ្ធិចំនួនប្រាំ (០៥)រូប និងសមាជិកជំនួសចំនួនប្រាំ (០៥)រូប បោះឆ្នោតជ្រើសរើសក្នុងចំណោម គ.ទ.ខ. ក្នុងភូមិភាគ ។ គ.ទ.ខ. នីមួយៗត្រូវជ្រើសរើសតំណាងរបស់ខ្លួនឱ្យបានយ៉ាងតិចមួយរូបពេញសិទ្ធិ និងមួយរូប ជាជំនួយ ចំនួនអាសនៈដែលនៅសល់ត្រូវបែងចែកទៅខេត្ត ក្រុង ដោយផ្អែកទៅលើចំនួនទន្តពេទ្យ ដែលបានចុះឈ្មោះ ជាសមាជិកក្រុមប្រឹក្សាភូមិភាគ ។ សមាជិកក្រុមប្រឹក្សាភូមិភាគ ត្រូវបានបោះឆ្នោត ជ្រើសរើសសម្រាប់រយៈពេល ប្រាំមួយ (០៦)ឆ្នាំ ។

សមាជិកចប់អាណត្តិអាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសរើសជាថ្មីឡើងវិញបាន ។ ក្រុមប្រឹក្សាធ្វើការបោះឆ្នោតជ្រើសរើសប្រធាន និងការិយាល័យរបស់ខ្លួន នៅក្នុងរយៈពេលពីរ (០២)ឆ្នាំម្តង ក្រោយពីបានធ្វើការផ្លាស់ប្តូរចំនួន១/៣ នៃសមាជិកក្រុមប្រឹក្សា ។ សមាជិកជំនួយត្រូវចូលជំនួសសមាជិកពេញសិទ្ធិ នៅពេលដែលសមាជិកនេះអវត្តមានដោយមូលហេតុអ្វីក៏ដោយ ។

**មាត្រា ២១.-**

ប្រធាន គ.ទ.ភ. ប្រធាន គ.ទ.ខ. និងអគ្គលេខាធិការនៃក្រុមប្រឹក្សាទាំងនេះ មិនអាចកាន់មុខងារត្រួតគ្នាបានឡើយ ។

**មាត្រា ២២.-**

អង្គប្រជុំ គ.ទ.ភ. ត្រូវបានចូលរួមក្នុងឋានៈជាអនុប្រធាន និងជាអ្នកពិគ្រោះយោបល់ដោយ ÷

- តំណាងឱ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល
- ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ដែលជាទីតាំងនៃក្រុមប្រឹក្សាភូមិភាគ
- ទីប្រឹក្សាច្បាប់មួយរូប ចាត់តាំងដោយប្រធានតុលាការនៃខេត្ត ក្រុង នោះ
- ទន្តពេទ្យការងារមួយរូបបើមាន ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- នាយកសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រភូមិភាគ ។

**មាត្រា ២៣.-**

នៅក្នុងក្របខ័ណ្ឌគណៈទន្តពេទ្យ គ.ទ.ភ. អនុវត្តការងាររបស់ខ្លួនតែទៅលើសមត្ថកិច្ចខាងវិន័យតែប៉ុណ្ណោះ ។

ក.ទ.ភ. អាចទទួលពាក្យបណ្តឹងជំទាស់ពី ក.ទ.ជ. ក.ទ.ខ. សមាគមទន្តពេទ្យ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានមន្ទីរសុខាភិបាល អាជ្ញាធរខេត្ត ក្រុង ព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង ឬសាមីទន្តពេទ្យ ដែលបានចុះឈ្មោះនៅក្នុងបញ្ជីគណៈទន្តពេទ្យ ។

ក.ទ.ភ. ត្រូវពិនិត្យសម្រេចនៅក្នុងរយៈពេលប្រាំមួយ (០៦)ខែយ៉ាងយូរ ក្រោយបានទទួលពាក្យបណ្តឹង ។ បើមិនដូច្នេះទេ កទ.ជ. អាចបញ្ជូនពាក្យបណ្តឹងនេះទៅ ក.ទ.ភ. ណាមួយផ្សេងទៀតដែលបានជ្រើសរើស ។

## មាត្រា ២៤.-

ទន្តពេទ្យដែលកំពុងបម្រើការនៅក្នុងសេវាសាធារណៈ ហើយបានសុំចុះឈ្មោះនៅក្នុងបញ្ជីគណៈទន្តពេទ្យនឹងអាចអញ្ជើញមកបកស្រាយនៅចំពោះមុខ ក.ទ.ភ. បាន ចំពោះសកម្មភាពក្នុងមុខងារសាធារណៈរបស់ខ្លួនតែតាមរយៈរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមរយៈប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ឬតាមរយៈព្រះរាជអាជ្ញាអមតុលាការតែប៉ុណ្ណោះ ។

## មាត្រា ២៥.-

ការដាក់ទោសវិន័យត្រូវធ្វើឡើងនៅចំពោះមុខ ទន្តពេទ្យសាមីត្រូវតែមានអ្នកការពារដែលជាទន្តពេទ្យ ឬជាមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។

## មាត្រា ២៦.-

ក.ទ.ភ. ត្រូវមានបញ្ជីកត់ត្រាការជំនុំជម្រះកាត់សេចក្តីនៅរាល់សវនាការនីមួយៗ ។ គេត្រូវធ្វើកំណត់ហេតុត្រឹមត្រូវដោយមានការបញ្ជាក់ និងចុះហត្ថលេខាពីគ្រប់សមាជិកទាំងអស់នៃក្រុមប្រឹក្សា ព្រមទាំងហត្ថលេខារបស់សាមីជនដែលត្រូវគេចោទសួរនោះផង ។

## មាត្រា ២៧.-

ក.ទ.ភ. ដោយមានការចូលរួមពីផ្នែកវិន័យនៃ ក.ទ.ជ អាចដាក់វិន័យដូចខាងក្រោម ÷

១- ការព្រមាន ។

២- សេចក្តីបន្ទោសដោយកត់ទុកក្នុងឯកសារផ្ទាល់ខ្លួន ។

៣- ហាមប្រកបវិជ្ជាជីវៈ មួយរយៈពេលមិនលើសពីបី (០៣) ឆ្នាំ ឬជាអចិន្ត្រៃយ៍ក្នុងផ្នែកណាមួយ ឬជាទូទៅនៃមុខងារ ទន្តសាស្ត្រដែលរដ្ឋទទួលស្គាល់ ។

៤- ការលុបឈ្មោះចេញពីបញ្ជីគណៈទន្តពេទ្យ ។

ទន្តពេទ្យដែលបានទទួលវិន័យត្រូវបាត់សមាជិកភាពនៅក្នុង ក.ទ.ខ. ក.ទ.ភ. ក.ទ.ជ. ក្នុងរយៈពេលមួយ (០១) ដល់បី (០៣) ឆ្នាំ ចំពោះវិន័យថ្នាក់ទីមួយ(០១) និងទីពីរ(០២) និងបាត់បង់ជាអចិន្ត្រៃយ៍ចំពោះវិន័យថ្នាក់ទីបី (០៣) និងទីបួន(០៤) ។



13

ទន្តពេទ្យដែលត្រូវលុបឈ្មោះពីបញ្ជី មិនអាចសុំចុះឈ្មោះនៅកន្លែងណាបានឡើយ ។

សេចក្តីដែលបានសម្រេចចុងក្រោយដែលបានលើកឡើងត្រូវតែផ្សព្វផ្សាយនៅគ្រប់ ក.ទ.ខ. ព្រមទាំងទៅ ក.ទ.ជ. ។ ការសម្រេចរបស់ ក.ទ.ភ. ត្រូវតែមានហេតុផលច្បាស់លាស់ ។

**មាត្រា ២៨.-**

ក្រោយបានទទួលការលុបឈ្មោះចេញពីបញ្ជីអស់រយៈកាលបី (០៣) ឆ្នាំយ៉ាងតិចមក ទន្តពេទ្យពាក់ព័ន្ធអាចទទួលការលើកលែងវិន័យអំពីក្រុមប្រឹក្សាគណៈទន្តពេទ្យដែលបានដាក់វិន័យដល់ខ្លួន ។ ការសុំលើកលែងវិន័យនេះត្រូវធ្វើឡើងដោយទន្តពេទ្យសាមី ។ កាលណាលិខិតស្នើសុំលើកលែងវិន័យនេះត្រូវបានបដិសេធក្រោយពីបានធ្វើការពិនិត្យពិចារណាស៊ីជម្រៅមក ការស្នើសុំលើកលែងវិន័យសារជាថ្មីនឹងអាចធ្វើទៅបានតែក្នុងរយៈកាលមួយឆ្នាំទៅមុខទៀត ។

**មាត្រា ២៩.-**

ការអនុវត្តន៍វិន័យរបស់ទន្តពេទ្យ មិនមែនជាឧបសគ្គរាំងដល់ការអនុវត្តន៍ការដាក់វិន័យ ចំពោះអំពើខុសឆ្គងដូចខាងក្រោមនេះឡើយ÷

១-ការចោទប្រកាន់ដែលរដ្ឋអំណាចសាធារណៈ ឬឯកជនអាចប្តឹងចំពោះតុលាការពីបទរដ្ឋប្បវេណី ។

២- សកម្មភាពស៊ីវិល ដើម្បីជួសជុលសងជម្ងឺចិត្ត ពីបទល្មើសថ្នាក់មជ្ឈិម ។

៣- ការដាក់វិន័យផ្នែករដ្ឋបាល នៅកន្លែងធ្វើការរបស់ទន្តពេទ្យ ។

៤- អំពើខុសឆ្គងដែលទន្តពេទ្យបានប្រព្រឹត្តដោយរំលោភបំពាន ក្នុងការចូលរួមថែទាំទន្តសាស្ត្រដែលបានគ្រោងនៅច្បាប់សង្គម ។

## ផ្នែកទី ៣
## ក្រុមប្រឹក្សាគណៈទន្តពេទ្យថ្នាក់ជាតិ

**មាត្រា ៣០.-**

ក្រុមប្រឹក្សាគណៈទន្តពេទ្យថ្នាក់ជាតិសរសេរកាត់ថា ក.ទ.ជ. ត្រូវបានជ្រើសរើសដោយបោះឆ្នោតសម្រាប់រយៈពេលប្រាំមួយ (០៦) ឆ្នាំ បែងចែកដូចខាងក្រោម÷

-តំណាងអោយខេត្ត ក្រុង នីមួយៗចំនួនមួយ (០១) រូប ចាត់តាំងដោយប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង

-តំណាងអោយរាជធានីភ្នំពេញចំនួនពីរ (០២) រូប ចាត់តាំងដោយប្រធានមន្ទីរសុខាភិបាលរាជធានី ភ្នំពេញ

-តំណាងអង្គភាពថ្នាក់កណ្តាលចំនួនប្រាំ (០៥) រូប ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល

-តំណាងអោយសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលចំនួនមួយ (០១) រូប ជ្រើសរើសដោយសហភាគរះរបស់គេ ។



10/13

**មាត្រា ៣១.-**

គ.ទ.ជ. ត្រូវធ្វើការជ្រើសរើសផ្លាស់ប្តូរសមាជិកចំនួនមួយភាគបី(១/៣) ក្នុងរយៈពេលពីរ (០២)ឆ្នាំម្តង ក្រោយពីបានធ្វើការផ្លាស់ប្តូរ សមាជិកមួយភាគបី (១/៣) ម្តងៗ ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ត្រូវធ្វើការជ្រើសរើស ប្រធាន និងការិយាល័យរបស់ខ្លួនសម្រាប់ ពីរ (០២) ឆ្នាំ ។

ការិយាល័យរបស់ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិកម្ពុជារួមមាន : ប្រធានក្រុមប្រឹក្សាមួយ (០១)រូប អនុប្រធានចំនួនពីរ (០២)រូប អគ្គលេខាធិការមួយ (០១)រូប អគ្គលេខាធិការរងមួយ (០១)រូប ហិរញ្ញិកមួយ (០១) រូប និងហិរញ្ញិករងមួយ (០១)រូប ។ ប្រធាន និងសមាជិក គ.ទ.ជ. ដែលចេញពីតំណែងអាចឈរឈ្មោះអោយគេជ្រើសរើសសារជាថ្មីបាន ។

**មាត្រា ៣២.-**

គ.ទ.ជ. មានជំនួយការជាទន្តពេទ្យចំនួនពីរ (០២)រូប តំណាងអោយរដ្ឋមន្ត្រីក្រសួងសុខាភិបាលមួយ (០១) រូប និងតំណាងអោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមួយ (០១)រូប ក្នុងឋានៈជាអនុប្រធាន និងមានសម្លេងពិគ្រោះយោបល់ ។

**មាត្រា ៣៣.-**

គ.ទ.ជ. មានផ្នែកវិន័យត្រូវមានសមាជិកប្រាំ (០៥)រូប ដឹកនាំដោយប្រធានមួយ (០១)រូប ជ្រើសតាំងក្នុងចំណោមសមាជិកប្រាំពីរ (០៧)រូបនេះ ។

**មាត្រា ៣៤.-**

បន្ទាប់ពីបានធ្វើការផ្លាស់ប្តូរសមាជិកចំនួន១/៣ របស់ខ្លួន គ.ទ.ជ. ត្រូវធ្វើការបោះឆ្នោតជ្រើសរើសផ្នែកវិន័យសារជាថ្មី ។

**មាត្រា ៣៥.-**

គ.ទ.ជ. បំពេញតួនាទីថ្នាក់ជាតិរបស់ខ្លួនពេលបេសកកម្មដែលមានចែងនៅក្នុងមាត្រា២ នៃព្រះរាជក្រឹត្យនេះ ។

គ.ទ.ជ.ឃ្លាំមើលជាអាទិ៍ការគោរពអនុវត្តតាម របស់សមាជិកនៃគណៈទន្តពេទ្យទាំងអស់ ចំពោះករណីយកិច្ចវិជ្ជាជីវៈ និងគោលការណ៍ទាំងឡាយដែលបានកំណត់នៅក្នុងក្រមសីលធម៌ទន្តពេទ្យ ។

គ.ទ.ជ. សហការជាមួយ គ.ទ.ខ. ធ្វើការសិក្សាដោះស្រាយនូវបញ្ហាស្មុគស្មាញទាំងឡាយដែលពាក់ព័ន្ធទៅនឹងប្រព្រឹត្តកម្មវិជ្ជាជីវៈរបស់ទន្តពេទ្យ ។

គ.ទ.ជ. បំពេញការងារនេះតាមរយៈផ្នែក និងគណៈកម្មការទាំងឡាយរបស់ខ្លួន និងពិនិត្យសិក្សានូវបណ្តាបញ្ហា ឬគម្រោងការណ៍ទាំងឡាយដែលបានលើកឡើងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬស្ថាប័នពាក់ព័ន្ធផ្សេងៗ ។

**មាត្រា ៣៦.-**

ក.ទ.ជ. ត្រូវកំណត់អំពីចំនួនទឹកប្រាក់ វិភាគទានឯកភាពមួយ ដែលសមាជិកម្នាក់ៗត្រូវបង់នៅពេលសុំចុះឈ្មោះ និងត្រូវបង់ប្រចាំឆ្នាំ ។

ក.ទ.ជ. ត្រូវកម្រិតផងដែរនូវចំនួនវិភាគទានដែល ក.ទ.ខ. ត្រូវបង់ជូនទៅ ក.ទ.ជ. ទៅ ក.ទ.ភ. នឹងត្រូវរក្សាទុកនៅក្នុង ក.ទ.ខ. ដើម្បីធានាចំណាយក្នុងការបំពេញការងារជាទូទៅ ។ ការបង់វិភាគទាន គឺជាកាតព្វកិច្ចរបស់សមាជិកម្នាក់ៗ ។ ក.ទ.ជ. គ្រប់គ្រងទ្រព្យសម្បត្តិទាំងអស់របស់គណៈទន្តពេទ្យ និងអាចបង្កើត ឬឧបត្ថម្ភដល់វណ្ណកម្មទាំងឡាយដែលជាផលប្រយោជន៍នៃវិជ្ជាជីវៈទន្តសាស្ត្រ ព្រមទាំងការងារសង្គ្រោះផ្សេងៗ ។

ក.ទ.ជ. ត្រួតពិនិត្យការគ្រប់គ្រងរបស់ ក.ទ.ខ. និងក.ទ.ភ. ។ ក.ទ.ខ. ត្រូវរាយការណ៍ជូន ក.ទ.ជ. ជាមុនចំពោះការបង្កើតអង្គការទាំងឡាយរបស់ខ្លួន ព្រមទាំងការចាត់ចែងរបស់អង្គការទាំងនោះ ។

**មាត្រា ៣៧.-**

ក.ទ.ជ. ត្រូវបង្កើតគណៈកម្មការមួយ សម្រាប់ចាត់ចែងហិរញ្ញវត្ថុ និងធ្វើសវនកម្មផ្ទៃក្នុង ។ សមាជិកនៃគណៈកម្មការនេះត្រូវជ្រើសរើសដោយ ក.ទ.ជ.ក្នុងចំណោមសមាជិកដែលមិនស្ថិតនៅក្នុងការិយាល័យនៃក្រុមប្រឹក្សា ។

ក្នុងដំណាច់ឆ្នាំនីមួយៗ គណៈកម្មការនេះ ត្រូវធ្វើរបាយការណ៍អំពីការត្រួតពិនិត្យរបស់ខ្លួនជូន ក.ទ.ជ. ។

## ជំពូកទី ៤
## អន្តរប្បញ្ញត្តិ

**មាត្រា ៣៨.-**

ក្នុងកំឡុងពេលប្រាំមួយ (០៦)ឆ្នាំដំបូង នៃអាណត្តិទី១សមាសភាពការិយាល័យរបស់ ក.ទ.ខ. ត្រូវបានជ្រើសតាំងដោយសហភាគរៈរបស់ខ្លួន និងទទួលស្គាល់ដោយ ក.ទ.ជ.។

សមាភាព ក.ទ.ជ. ក្នុងអណត្តិទី១ ត្រូវបានជ្រើសតាំង ដើម្បីដំណើរការអោយមានប្រសិទ្ធភាព ។

**មាត្រា ៣៩.-**

រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវតែងតាំងក្រុមការងារមួយជាបណ្ដោះអាសន្ន ដើម្បីរៀបចំដំណើរការបង្កើតគណៈទន្តពេទ្យកម្ពុជា ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ៤០.-**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរល.០៩០៥.៤១៧

**បានយកសេចក្តីក្រាបបង្គំទូលថ្វាយ**
**ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា**
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

លេខ ...៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible]